# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស/(អបជ៦០) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Mar-2020, 09:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. Hollis
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៍យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សុំឆ្លើយតបទៅនឹងសំណើរបស់ អោ អាន ដែលស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើង ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ("សំណើរបស់ អោ អាន")[1]។ ខណៈដែល អោ អាន លើកឡើងត្រឹមត្រូវថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ចាំបាច់ត្រូវធ្វើឡើង[2] គាត់លើកឡើងខុសអំពីវិធានការដែលតម្រូវ គឺថា អ.ប.ជ ជាប់កាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង និងយុត្តិសាស្ត្រ ក្នុងការបញ្ជូនសំណុំរឿងនេះ (រួមបញ្ចូលទាំងដីកបញ្ជូនរឿងទៅជំនុំជម្រះ) ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ")។

2. កាតព្វកិច្ចនេះច្បាស់លាស់ណាស់ ហើយវាធានាឱ្យមានសវនាការសមរម្យ ដែលសិទ្ធិទទួលបានការជំនុំជម្រះដ៏ត្រឹមត្រូវរបស់ អោ អាន នឹងត្រូវបានការពារ ហើយសំឡេងរបស់ជនរងគ្រោះទាំងនៅរស់ និងបាត់បង់ជីវិត នឹងត្រូវបានស្តាប់ឮ។ ដូចដែលអ្នករស់រានមានជីវិតនៃ Holocaust និងជ័យលាភីណូបែល Elie Wiesel បានថ្លែងថា៖ "បំភ្លេចជនរងគ្រោះ គឺជាការសម្លាប់ពួកគេជាលើកទីពីរ។ [យើង] មិនអាចទប់ស្កាត់ការស្លាប់ដំបូងបាន។ [យើង] ពិតជាត្រូវតែមានលទ្ធភាពជួយសង្គ្រោះពួកគេពីការស្លាប់ជាលើកទីពីរ"[3]។ អ្នកស្លាប់ទៅហើយមិនអាចនិយាយចេញពីផ្នូរបានទេ។ ភ័ស្តុតាងដែលបង្ហាញនៅពេលជំនុំជម្រះគឺជាសំឡេងរបស់ពួកគេ។ ចៅក្រមឯករាជ[4] នៃស្ថាប័នតុលាការឯករាជមិនត្រូវបដិសេធសំឡេងនោះរបស់ពួកគេទេ។

---

[1] ឯកសារ **D359/27** សំណើសុំបញ្ជាក់ថា វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង០០៤/០២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២០ ("សំណើរបស់ អោ អាន")។

[2] ទោះបីជាវិធានការរដ្ឋបាលទាំងនេះចាំបាច់ត្រូវចាត់វិធានការដោយ អ.ប.ជ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងបានចូលមើលសំណុំរឿងភ្លាមៗយ៉ាងណាក៏ដោយក៏ អ.ជ.ស.ដ ឥឡូវនេះបានទទួលសំណុំរឿងផ្អែកតាមសេចក្តីពិចារណារបស់ អ.ប.ជ តាមវិធាន ៧៧(១៣)(ខ) និង វិធាន ៧៩(១)។ ជាផលវិបាក អ.ជ.ស.ដ មានករណីយកិច្ចស្តាប់សំណុំរឿងនេះ ដោយមិនគិតថាតើសំណុំរឿងនេះត្រូវបានបញ្ជូនភ្លាមៗទៅឱ្យ អ.ជ.ស.ដ ដោយ អ.ប.ជ ឬយ៉ាងណានោះទេ។ *សូមមើល* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដូចដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ៧៧(១៣)(ខ) និង ៧៩(១)។

[3] NPR, *Elie Wiesel, Holocaust Survivor and Nobel Laureate, Dies at 87* ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៦ ទំព័រទី ២។

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៣(៣)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម

3. ដូចដែលបានពិភាក្សាខាងក្រោម សំណើរបស់ អោ អាន គួរតែត្រូវបានច្រានចោល ដោយសារតែវាព្យាយាមមិនត្រឹមត្រូវក្នុងការគេចវេសចេញពីក្របខណ្ឌច្បាប់ អ.វ.ត.ក ដែលកំណត់អំពីផលវិបាកនៃស្ថានភាពបច្ចុប្បន្ន ឬម្យ៉ាងវិញទៀត *សម្រាប់គោលបំណងវែកញែក* ប្រសិនបើ អ.ប.ជ កំណត់ថា សំណុំរឿងនេះគួរត្រូវរក្សាទុកក្នុងបណ្ណសារមែននោះ សំណើរបស់ អោ អាន គឺធ្វើឡើងមុនពេលកំណត់។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានជូនដំណឹងអំពីសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤/២ នេះ[5] ដែលតម្រូវឱ្យបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់[6] ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[7]។

5. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានដាក់សំណើមួយទៅកាន់ អ.ប.ជ ស្នើសុំឱ្យ អ.ប.ជ ចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង[8]។ មកទល់នឹងកាលបរិច្ឆេទនៃចម្លើយតបនេះ អ.ប.ជ មិនទាន់ចេញសេចក្តីសម្រេចលើបញ្ហានេះនៅឡើយទេ ហើយសំណុំរឿងក៏មិនទាន់បានបញ្ជូនទៅដែរ។

## III. ច្បាប់ជាធរមាន

6. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

---

ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ អ.វ.ត.ក”) មាត្រា ១០ថ្មី។

[5] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (“សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ”) កថាខណ្ឌ ១៦៩ ផ្នែកសម្រេចសេចក្តី ត្រង់ KH01634853។

[6] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាសម្រេចលើកលែងចោទប្រកាន់”)។

[7] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”)។

[8] ឯកសារ **D359/25** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ (“សំណើសុំឱ្យបញ្ជូនរបស់ ស.ព.អ”)។

ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ [...] **ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត**[9]។

7. មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។ [...] **ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត**[10]។

8. វិធាន២ នៃវិធានផ្ទៃក្នុង ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ [...] អង្គជំនុំជម្រះត្រូវធ្វើការ សម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង និង មាត្រា ៣៣ ថ្មី ឬមាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។

9. វិធាន ២១(១) ចែងថា៖

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ **និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព** ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖ ក-ដំណើរការនីតិវិធីនៅក្នុង

[9] គូសបញ្ជាក់បន្ថែម។

[10] គូសបញ្ជាក់បន្ថែម។

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ **ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ** [...][11]។

10. វិធាន ៧៧(១៣) ចែងថា៖

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ **សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្រ**របស់អង្គបុរេជំនុំជម្រះ**ត្រូវ**អនុវត្តដូចខាងក្រោម៖

ក-ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ ។

ខ-ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត **ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយ**របស់សហចៅក្រមស៊ើបអង្កេត[12]។

11. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

## IV. **សារណា**

### ***សំណើរបស់ អោ អាន ត្រូវតែបដិសេធចោល ដោយសារវាព្យាយាមគេចវេសចេញពីក្របខណ្ឌច្បាប់ អ.វ.ត.ក ដែលកំណត់ថារឿងក្ដីនេះត្រូវតែបញ្ជូនទៅជំនុំជម្រះ***

12. សំណើរបស់ អោ អាន មើលរំលងក្របខណ្ឌច្បាប់ អ.វ.ត.ក ដែលគាត់ខ្លួនឯងផ្ទាល់បានយោងនៅក្នុងកថាខណ្ឌ១៧ - ជាពិសេស ឥទ្ធិពលផ្លូវច្បាប់នៃការបរាជ័យក្នុងការទទួលបានសំឡេងភាគច្រើន

---

[11] គូសបញ្ជាក់បន្ថែម។

[12] គូសបញ្ជាក់បន្ថែម។

លើសលុបរបស់ អ.ប.ជ ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានចេញនៅក្នុងរឿងក្ដីនេះ - និងផ្ដោតលើការបែកចេញពីគ្នាមិនពាក់ព័ន្ធរវាងចៅក្រមបីនាក់ និងចៅក្រមពីរនាក់នៃចៅក្រម អ.ប.ជ[13]។ ពាក្យ "មិនពាក់ព័ន្ធ" ត្រូវបានប្រើដោយមានគោលបំណង ដោយហេតុថា មានតែសំឡេងភាគច្រើនលើសលុបដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ដែលអាចរារាំងរឿងក្ដីនេះមិនឲ្យបន្តទៅមុខដើម្បីជំនុំជម្រះ[14]។ ទោះបីជា ការលើកឡើងជាដដែលៗរបស់ អោ អាន ក៏ដោយ ក៏សំឡេងភាគច្រើនធម្មតាមិនមានទម្ងន់ណាមួយនៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក ឡើយ។

13. ផ្ទុយទៅនឹងអំណះអំណាងគ្មានមូលដ្ឋានរបស់ អោ អាន និងដូចដែលមានរៀបរាប់នៅក្នុងសារណាផ្សេងទៀតរបស់ ស.ព.អ[15] ក្របខណ្ឌនោះដោះស្រាយការជាប់គាំងណាមួយដែលនៅមានបន្ទាប់ពី

---

[13] ឯកសារ **D359/27** សំណើរបស់ អោ អាន កថាខណ្ឌ ១៦, ១៧។

[14] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ឯកសារ **D324.30** លិខិតពីអគ្គលេខាធិការ អ.ស.ប ចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ចំណារដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ពីលោក Hans Corell ទៅកាន់លោកអគ្គលេខាធិការ ប្រធានបទ៖ សេចក្ដីអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសដើម្បីដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01326090 (នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្ដល់ជាលើកដំបូងនូវមាត្រា ៧(៤) ដែលសរសេរទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell អគ្គលេខាធិការរងទទួលបន្ទុកផ្នែកកិច្ចការច្បាប់ និងក្រុមប្រឹក្សាច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាមួយជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានក្រុមចរចាររបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការច្រានចោលនូវការអំពាវនាវរបស់គាត់ឲ្យមានលក្ខខណ្ឌតម្រូវមតិភាគច្រើនដាច់ខាតដើម្បី *អនុម័តឲ្យមាន* ការបន្តការស៊ើបសួរ ឬការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានព្រាងនេះ មានន័យថា "អ្នកត្រូវការមតិភាគច្រើនដាច់ខាត ដើម្បីបញ្ឈប់ការស៊ើបសួរ ឬការចោទប្រកាន់")។ ឯកសារ **D324.36** សេចក្ដីថ្លែងការណ៍ដោយលោក Hans Corell អគ្គលេខាធិការរង នៅពេលដែលចាកចេញពីភ្នំពេញនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ EN 01326112។ ឯកសារ **D359/3/1.1.43** លោក David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពផ្សាយលើកទី៣ វ៉ុល្លូមIII ឆ្នាំ២០០៨ ទំព័រ២៤៦ (EN 01598756) (លោក David Scheffer ដែលជាឯកអគ្គរដ្ឋទូតគោចររបស់ ស.រ.អា សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងបានចូលរួមយ៉ាងច្រើននៅក្នុងកិច្ចចរចារ អ.វ.ត.ក បានបញ្ជាក់ទស្សនៈដូចគ្នាថា៖ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបសួរត្រូវបាន *បញ្ឈប់* នោះគឺ ប្រសិនបើ [អ.ប.ជ] សម្រេចដោយសំឡេងភាគច្រើនលើសលុប ថាវាគួរតែបញ្ឈប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំងមិនឲ្យ [ស.ច.ស] ឬ សហព្រះរាជអាជ្ញាណាម្នាក់ រាំងខ្ទប់ដល់ការស៊ើបសួរ ឬ ការចោទប្រកាន់ណាមួយ ដោយការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាមួយជាមួយនឹងដៃគូរបស់ខ្លួន ឬក៏ ដោយគ្រាន់តែបង្អាក់ការស៊ើបសួរ ឬការចោទប្រកាន់ បណ្ដាលមកពីឥទ្ធិពលនយោបាយ ឬឥទ្ធិពលប្រភេទផ្សេងៗទៀត" (គូសបញ្ជាក់បន្ថែម))។

[15] *សូមមើល ឧទា.* ឯកសារ **D359/25** សំណើសុំឲ្យបញ្ជូនរបស់ ស.ព.អ កថាខណ្ឌ ២។ ឯកសារ **D359/28** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង ចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ សុំឲ្យចាត់រាល់វិធានការ

អ.ប.ជ បានសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ភាគី។ វិធាន ៧៧(១៣)(ខ) ដែលអនុវត្តគោលបំណង និងបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក[16] ដំណើរការជា*វិធានពិសេស* *(lex specialis)* ហេតុដូច្នេះ មានអានុភាពលុបលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក)។ វិធាន ៧៧(១៣)(ខ) ឆ្លុះបញ្ចាំងអំពីចេតនាច្បាស់លាស់របស់កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដែលវាចង្អុលបង្ហាញថា ក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបទេនោះ **គោលជំហរស្វ័យប្រវត្តិត្រូវ** ប្ដឹងទៅ អ.ជ.ស.ដ អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ។ ដូច្នេះ វិធាននេះ និងវិធាន ៧៩(១) ដែលស្របគ្នាទៅនឹងវិធាននេះដោះស្រាយការជាប់គាំងណាមួយ។

14. ជាងនេះទៀត ករណីបន្ទាន់នេះមិនពាក់ព័ន្ធទៅនឹង "ចៅក្រមពីររូប [មានអានុភាពលុបលើ] ការយល់ឃើញរបស់មតិភាគច្រើន ឬ [បង្គាប់] ជាឯកត្តោភាគីដល់ក្រឡាបញ្ជី អ.ប.ជ ក្នុងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង" ដូចដែល អោ អាន អះអាងនោះទេ[17]។ ផ្ទុយទៅវិញ ក្រមខណ្ឌច្បាប់ អ.វ.ត.ក ធ្វើឱ្យការបែកចេញពីគ្នា ៣/២ រវាងចៅក្រមទាំងនេះ មិនពាក់ព័ន្ធ ហើយតម្រូវថា សំណុំរឿងនេះ រួមបញ្ចូលទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនទៅកាន់ អ.ជ.ស.ដ ដែលត្រូវបានប្ដឹងឱ្យទទួលយករឿងក្ដីនេះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[18]។

15. អំណះអំណាងគ្មានមូលដ្ឋានរបស់ អោ អាន ដែលថា អ្នកឈ្នះក្នុងការប្រណាំងប្រជែងដាក់ដីកាដំណោះស្រាយ មានអានុភាពលុបលើ គឺមិនពាក់ព័ន្ធដូចគ្នា។ គាត់មិនបានចង្អុលបង្ហាញចំណុចណាមួយទាល់តែសោះនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង ឬ យុត្តិសាស្ត្រដែលនឹងគាំទ្រអំណះអំណាងខ្លែងក្លាយរបស់គាត់នេះ[19]។ ក្នុងករណីណាក៏ដោយ ស.ព.អ កត់សម្គាល់ថា ត្រានៅលើដីកាដំណោះស្រាយបញ្ជាក់ថា ដីកាសម្រេចលើកលែងចោទប្រកាន់

---

រដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ("ការឆ្លើយតបសុំឱ្យបញ្ជូនរបស់ ស.ព.អ") កថាខណ្ឌ ៣, ៥, ៨។

[16] *សូមមើល* កំណត់សម្គាល់ជើងទំព័រលេខ១៤ *យោងខាងលើ*។

[17] ឯកសារ **D359/27** សំណើរបស់ អោ អាន កថាខណ្ឌ ១៦។

[18] *សូមមើលផងដែរ* ឯកសារ **D359/25** សំណើសុំឱ្យបញ្ជូនរបស់ ស.ព.អ កថាខណ្ឌ ២, ២៣, ២៥។ ឯកសារ **D359/28** ការឆ្លើយតបសុំឱ្យបញ្ជូនរបស់ ស.ព.អ កថាខណ្ឌ ៥។

[19] ឯកសារ **D359/27** សំណើរបស់ អោ អាន កថាខណ្ឌ ១៧។

មិនត្រូវបានដាក់មុនទេ៖ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាដំណោះស្រាយទាំងពីរនៅម៉ោង ៨:១០នាទីព្រឹក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[20]។

16. អំណះអំណាងរបស់ អោ អាន ទាក់ទងនឹង *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺគ្មានមូលដ្ឋានដូចគ្នា[21]។ គោលការណ៍នេះមិនអាចអនុវត្តចំពោះបញ្ហានីតិវិធី ដូចក្នុងករណីនេះទេ ដូចដែលបានបង្ហាញយ៉ាងពេញលេញនៅក្នុងការឆ្លើយតបថ្មីៗនេះរបស់ ស.ព.អ នៅចំពោះមុខអង្គជំនុំជម្រះនេះ ទាក់ទងនឹងការបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ[22]។

## *សំណើរបស់ អោ អាន ត្រូវតែបដិសេធចោលពីព្រោះវាមុនពេលកំណត់*

17. ក្នុងករណីដែលថា *សម្រាប់គោលបំណងវែកញែក* អ.ប.ជ សម្រេចថា ខ្លួននឹងរក្សាសំណុំរឿងទុកក្នុងបណ្ណសារ និងបិទសំណុំរឿងនេះ សំណើរបស់ អោ អាន ទោះជាយ៉ាងណាត្រូវតែបដិសេធចោលដោយហេតុថាធ្វើឡើងមុនពេលកំណត់។ វាមើលរំលងអ្វីដែល "ជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ចៅក្រម"[23] ដែលជា "ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស"[24] លើបញ្ហានានានៅចំពោះមុខ អ.ប.ជ ដែលនៅតែតម្រូវឱ្យមានដំណោះស្រាយ។ កត់សម្គាល់ថា អ.ប.ជ មិនទាន់បានប្រកាសលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងភាពអាចទទួលយកបាន សំណើរបស់ ស.ព.អ ទាក់ទងនឹងការពិនិត្យឡើងវិញនូវប្រតិចារឹកជាភាសាបារាំងមកពីសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងខែមិថុនា ឆ្នាំ២០១៩ និងសំណើរបស់ ស.ព.អ ដែលស្នើសុំថាឱ្យចាត់រាល់វិធានការរដ្ឋបាលទាំងអស់ដើម្បីបញ្ជូនសំណុំរឿងនេះទៅកាន់អង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[25]។

[20] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ (សំណៅជាភាសាខ្មែរ) គម្របក្បាលលិខិត។ ឯកសារ **D360** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (សំណៅជាភាសាអង់គ្លេស) គម្របក្បាលលិខិត។

[21] ឯកសារ **D359/27** សំណើរបស់ អោ អាន កថាខណ្ឌ ១៦-១៧។

[22] ឯកសារ **D359/28** ការឆ្លើយតបសុំឱ្យបញ្ជូនរបស់ ស.ព.អ កថាខណ្ឌ ៦-១០។

[23] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១២២។

[24] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១២២។

[25] ឯកសារ **D362/5** បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ ឯកសារ **D359/18** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យធ្វើការត្រួតពិនិត្យពេញលេញលើប្រតិចារឹកជាភាសាបារាំងនៃសវនាការបណ្តឹងឧទ្ធរណ៍ ដែលបានធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។ ឯកសារ **D359/25** សំណើសុំឱ្យបញ្ជូនរបស់ ស.ព.អ។

18. សំណើរបស់ អោ អាន ត្រូវតែបដិសេធចោលដោយហេតុថាធ្វើឡើងមុនពេលកំណត់ ពីព្រោះវាមើលរំលងថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែរក្សាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង[26]។ តុល្យភាពនេះតម្រូវថា មុនពេលដែលអង្គជំនុំជម្រះចាត់វិធានការបែបនេះ ភាគីនានា រួមទាំង ស.ព.អ និង ដើមបណ្តឹងរដ្ឋប្បវេណី ទទួលបានឱកាសស្នើសុំថា ការដាក់ឯកសារជាក់លាក់នានា ដូចជា សារណាបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងដីកាដំណោះស្រាយ ត្រូវធ្វើការកំណត់ចំណាត់ថ្នាក់ឡើងវិញពីសម្ងាត់ ទៅជាសាធារណៈវិញ។ ឱកាសបែបនេះទាមទារឱ្យមានដើម្បីធានាតម្លាភាពនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក[27]។

19. ស.ព.អ កត់សម្គាល់ដោយក្តីកង្វល់ថា បច្ចុប្បន្ននេះមិនមានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០៤/២ ទេ ហើយដោយសារតែអាសយដ្ឋានសារអេឡិចត្រូនិកមិនដំណើរការរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន វាមិនច្បាស់ទេថាតើ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងអំពីការវិវឌ្ឍន៍នានា និងស្ថានភាពបច្ចុប្បន្ននៃរឿងក្តី ០០៤/២ នេះ។ រក្សាសំណុំរឿងទុកក្នុងបណ្ណសារ និងបិទសំណុំរឿងនេះដោយគ្មានផ្តល់ឱកាសឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយតប នឹងរំលោភបំពានលើផលប្រយោជន៍នៃយុត្តិធម៌ និងគោលការណ៍ជាមូលដ្ឋានដែលផ្តល់ឱ្យចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក ដើម្បី "ធានាថាមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត" ស្របជាមួយនឹងការស្វែងរកការផ្សះផ្សារជាតិរបស់តុលាការនេះ[28]។

## V. សេចក្តីសន្និដ្ឋាន

20. អោ អាន អះអាងត្រឹមត្រូវថា ត្រូវតែមានការសម្រេចចុងក្រោយលើបញ្ហានេះ ប៉ុន្តែយល់ខុសទាំងស្រុងនូវអ្វីដែលជាការសម្រេចចុងក្រោយនោះ។ ដោយសារតែការបរាជ័យរបស់ អ.ប.ជ ក្នុងការទទួលបានសំឡេងភាគច្រើនលើសលុបដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ គោលជំហរ "ជាមូលដ្ឋាន និងជាកត្តាកំណត់"[29] ដែលមានចែងនៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក កំណត់

[26] វិធាន ២១(១)(ក), ២១(១)(គ) នៃវិធានផ្ទៃក្នុង។

[27] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។

[28] សំណុំរឿង០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៤-៦៥។ កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា។

[29] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា

ថា អ.ប.ជ ត្រូវបញ្ជូនសំណុំរឿងនេះ (រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជាបន្ទាន់ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។ ជាងនេះទៀត ការរក្សាទុករឿងក្ដីនេះក្នុងបណ្ណសារដោយគ្មានការជំនុំជម្រះ ធ្វើឲ្យក្ដីសង្ឃឹម និងសិទ្ធិទទួលបានយុត្តិធម៌កប់បាត់ក្នុងដីចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏ល្បីល្បាញទាំងអស់នេះ និងប្រជាជនកម្ពុជាទាំងអតីតកាល និងបច្ចុប្បន្ន។

21. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សំណើរបស់ អោ អាន ត្រូវតែច្រានចោល។

22. ដើម្បីជៀសវាងការពន្យារពេលបន្ថែមទៀត និងដើម្បីធានាឲ្យមានការជំនុំជម្រះដ៏ឆាប់រហ័ស ដូចដែលបានកំណត់ដោយមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើជាថ្មីម្ដងទៀតឲ្យ អ.ប.ជ បំពេញកិច្ចស្របតាមកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់តុលាការនេះ ដោយចាត់រាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនសំណុំរឿងនេះ (រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជាបន្ទាន់ទៅកាន់អង្គជំនុំជម្រះសាលាដំបូង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ | លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and stamp: CO-PROSECUTORS CO-PROCUREURS E.C.C.C. C.E.T.C.] |

ឆ្នាំ២០១០ កថាខណ្ឌ ១៥៧៤, ១៥៧៦ (ដែលនៅក្នុងនោះ ស.ច.ស ទាំងពីរនាក់ខ្វែងយោបល់គ្នាចំពោះផ្នែកសម្រេចសេចក្ដីនៃសំណុំរឿង ក៏ប៉ុន្តែដើម្បីចៀសវាងការជាប់គាំងខាងនីតិវិធី ទាំងពីរនាក់ក៏បានចោទប្រកាន់ជនត្រូវចោទ **ដោយបានបញ្ជូនសំណុំរឿងទៅជំនុំជម្រះ**)។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៧៤ (ដែលនៅក្នុងនោះ អ.ប.ជ បានសម្រេចថា វិធីសាស្ត្រនេះជាប់ទាក់ទងគ្នាជាមួយនឹងគោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត")។ ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១០៦ (ដែលនៅក្នុងនោះ អ.ប.ជ បានបញ្ជាក់ជាឯកច្ឆ័ន្ទលើការសម្រេចនេះ) កថាខណ្ឌ ១១៤-១១៥។